www.kidworship.kr

# ចំណងជើង៖ សាសន៍សាម៉ារី



48Page

**Narration** បណ្ឌិតខាងក្រិត្យវិន័យម្នាក់បានឈរនៅមុខព្រះយេស៊ូ ដើម្បីសួរចង់សាកល្បងទ្រង់។

**បណ្ឌិត** តើខ្ញុំត្រូវធ្វើដូចម្ដេចដើម្បី ទទួលបាននូវជីវិតអស់កល្ប?

**ព្រះយេស៊ូ** តើអ្វីដែលមានចែងទុកក្នុងក្រិត្យវិន័យ?

**បណ្ឌិត** គឺត្រូវស្រឡាញ់ព្រះអម្ចាស់ ជាព្រះនៃឯងឲ្យអស់ពីចិត្ត ព្រលឹងវិញ្ញាណ កំលាំង
និងគំនិតនៃឯង ហើយត្រូវស្រឡាញ់អ្នកជិតខាងឲ្យដូចស្រឡាញ់ខ្លួនឯងដែរ។

**ព្រះយេស** អ្នកនិយាយនេះត្រូវហើយ ធ្វើដូច្នេះអ្នកនឹងទទួលបាននូវជីវិតអស់កល្បជានិច្ច។

**Narration** ប៉ុន្តែ ដោយបណ្ឌិតខាងក្រិត្យវិន័យចង់បង្ហាញពីភាពត្រឹមត្រូវរបស់គាត់
គាត់ក៏បានសួរទៅកាន់ព្រះយេស៊ូថា៖

**បណ្ឌិត** តើនរណាគឺជាអ្នកជិតខាងរបស់ខ្ញុំ?

**Narration** ព្រះយេស៊ូបានឆ្លើយតបដោយប្រាប់រឿងមួយទៅកាន់គាត់។



49Page



50Page

**ព្រះយេស៊ូ** មានបុរសម្នាក់បានកំពុងតែធ្វើដំណើរពីក្រុងយេរូសាឡិម ទៅកាន់ក្រុងយេរីខូ
ពេលនោះគាត់បានធ្លាក់ទៅក្នុងកណ្ដាប់ដៃរបស់ពួកចោរ។

**ចោរទី១** ហេ!! ឯងឆាប់ឲ្យប្រាក់ និងសំលៀកបំពាក់របស់ឯងមកឲ្យយើងភ្លាម! ឲ្យវាមកនេះ!!
វាគឺជារបស់យើង!!

**បុរស** ទេ! សូមឲ្យវាមកខ្ញុំវិញមក!!

**ចោរទី២** យើងគិតថាប្រហែលជាឯងចង់បានមេរៀនខ្លះហើយមើល៍ទៅ!!
ផាំង ..ផាំង!!!

**បុរស** អា...អូយ..អូយ!!អូយ!!

**ព្រះយេស៊ូ** ចោរក៏បានឆក់យកបង្វិចរបស់គាត់ ហើយវៃគាត់ រួចក៏ចាកចេញទៅ
ធ្វើឲ្យគាត់រងរបួសស្ទើរតែស្លាប់។



51Page

**ព្រះយេស៊ូ** បុរសនោះមានការឈឺចាប់ជាខ្លាំង គាត់ពុំអាចក្រោករួចនោះទេ។
បន្ទាប់មកគាត់ក៏បានឮសំឡេងជើងមនុស្សដើរមក។ នោះគឺជាសំឡេងជើងរបស់សង្ឃ
ដែលនាំយកដង្វាយទៅថ្វាយព្រះនៅទីសក្ការបូជា។

**បុរស** (ក្នុងគំនិត) សង្ឃនេះគឺជាមនុស្សល្អ គាត់ប្រាកដជាជួយដល់ខ្ញុំ!!
សូមសង្គ្រោះខ្ញុំផង!! អូយ...អូយ...សូមជួយខ្ញុំផង!!

**ព្រះយេស៊ូ** ប៉ុន្តែនៅពេលដែលសង្ឃបានឃើញបុរសនោះ
គាត់ក៏បានដើរវាងតាមផ្លូវម្ខាងចេញបាត់ទៅ។

**ព្រះយេស៊ូ** មួយសន្ទុះក្រោយមក គាត់ក៏បានឮសំឡេងជើងមកទៀត។
នោះគឺជាសំឡេងជើងរបស់ពួកលេវី
ដែលជាអ្នកជំនួយដល់សង្ឃក្នុងកិច្ចការក្នុងទីសក្ការបូជា។


51Page

បុរស (ក្នុងគំនិត) អូយ....ពួកលេវីម្នាក់នេះគេនឹងជួយខ្ញុំ!
សូមជួយខ្ញុំផង.....សូមមេត្តា!... សូមមេត្តាជួយដល់ខ្ញុំផង!!

ព្រះយេស៊ូ ពួកលេវីក៏បានឃើញបុរសនោះបានដេកដួលនៅលើផ្លូវ
ប៉ុន្តែពួកគេបានដើរហួសទៅតាមផ្លូវផ្សេងទៀត។

........................................................................................................

ព្រះយេស៊ូ បុរសដែលរៀបនឹងស្លាប់ម្នាក់នេះគឺកាន់តែខ្សោយទៅៗ។
ក្រោយមកគាត់ក៏បានឮសំឡេងជើងផ្សេងមួយទៀតបានមក។សំឡេងជើងនោះគឺជាសំ
ឡេងជើងរបស់បុរសម្នាក់ដែលគាត់កំពុងតែជិះនៅលើខ្នងសត្វលារបស់គាត់។
គាត់គឺជាសាសន៍សាម៉ារី
គាត់បានមើលទៅជនជាតិអ៊ីស្រាអែលដែលកំពុងតែដេកដួលនៅលើផ្លូវ។

បុរស (ក្នុងគំនិត) សូម្បីតែពួកសង្ឃ និង ពួកលេវីពួកគេមិននឹងឈប់ជួយខ្ញុំផង! ពិតណាស់
សាសន៍សាម៉ារី ម្នាក់នេះក៏នឹងដើរចេញទៅផ្លូវមួយផ្សេងទៀតដែរ
ហ៊ឹម..ពេលនេះខ្ញុំបានបាត់បង់កំលាំងបណ្តើរៗហើយ
ខ្ញុំគិតថានេះគឺជាពេលស្លាប់របស់ខ្ញុំហើយ។


52Page

ព្រះយេស៊ូ បុរសម្នាក់នោះគាត់កាន់តែខ្សោយឡើងៗ
គាត់ស្ទើរតែបោះបង់ក្តីសង្ឃឹមរបស់គាត់ទៅហើយ
ប៉ុន្តែនៅពេលនោះគឺមានការអស្ចារ្យមួយ គឺបុរសសាម៉ារីបានចុះពីលើខ្នងលា
ហើយមកឯគាត់ រួចបានជួយសង្គ្រោះដឹគាត់។

សាសន៍សាមារី អូ! មិត្តសំឡាញ់អ្នកបានហូរឈាមច្រើនណាស់។ នៅតំបន់នេះមានចោរច្រើនណាស់
ដូច្នេះអ្នកត្រូវតែប្រុងប្រយ័ត្ន។


53Page

ព្រះយេស៊ូ សាសន៍សាម៉ារីបានជូតឈាមរបស់បុរសនោះចេញ
រួចសំអាតរបួសរបស់គាត់ជាមួយនឹងក្រមួន ដោយរុំបិទយ៉ាងប្រុងប្រយ័ត្ន។

........................................................................................................

ព្រះយេស ហើយសាសន៏សាម៉ារីបានលើកបុរសនោះដាក់នៅលើខ្នងលារបស់គាត់
ហើយនាំគាត់ទៅកាន់ផ្ទះសំណាក់។ គាត់បានមើលថែទាំបុរសនោះយ៉ាងល្អ
នៅថ្ងៃបន្ទាប់សាសន៍សាម៉ារីបានយកប្រាក់មួយចំនួន
ឲ្យទៅម្ចាស់ផ្ទះសំណាក់ហើយនិយាយថា៖

សាសន៍សាម៉ារី ខ្ញុំត្រូវចាកចេញឥឡូវនេះហើយ សូមថែទាំបុរសនេះផង
ប្រសិនបើអ្នកចំណាយលើសពីប្រាក់នេះ ពេលខ្ញុំត្រឡប់មកវិញខ្ញុំនឹងជូនបង្គ្រប់។

Narration បន្ទាប់ពីនិយាយរឿងនេះរួចហើយ ព្រះយេស៊ូបានសួរសំនួរទី១
របស់ទ្រង់ទៅកាន់បណ្ឌិតខាងក្រិត្យវិន័យ។


54Page

ព្រះយេស៊ូ មានមនុស្ស បីនាក់នៅក្នុងរឿងនេះគឺសង្ឃ ពួកលេវី និងសាសន៍សាម៉ារី
ក្នុងចំណោមមនុស្សទាំងបីនាក់ តើអ្នកយល់ថាអ្នកណាជាអ្នកជិតខាងយ៉ាងពិតប្រាកដរបស់
បុរសនោះ  នៅពេលដែលគាត់បានធ្លាក់ទៅក្នុងកណ្តាប់ដៃរបស់ពួកចោរ។

| | |
|---|---|
| បណ្ឌិត | គឺអ្នកដែលមានចិត្តមេត្តាករុណា និងជួយដល់គាត់ នោះគឺសាសន៍សាម៉ារី។ |
| ព្រះយេស៊ូ | ពិតជាត្រឹមត្រូវហើយ!! សូមលោកអញ្ជើញទៅចុះ ហើយប្រព្រឹត្តឲ្យដូចអ្នកនោះទៅ។ |
| **Narration** | ព្រះបន្ទូលរបស់ព្រះយេស៊ូបានធ្វើឲ្យបណ្ឌិតខាងក្រិត្យវិន័យ បានផ្លាស់ប្តូរអារម្មណ៍ ហើយគាត់បានត្រិះរិះគិតពិចារណាឡើងវិញ។ |